# ដណ្ឋៀយាត្រា

## ដើមពោធិ៍ - សាណាថ



**SARANATH**

ព.ស. ២៥០០

បោះពុម្ពផ្សាយចំនួន ៣០០០ ច្បាប់

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

- ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ក្រោមការឧបត្ថម្ភអំពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា អាត្មាភាពនាម **អ៊ុត ស៊ុំ** ស្រុកកំណើតនៅភូមិកំពោ ឃុំបឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ បានសាងផ្នួសជាលើកទី ២ នៅថ្ងៃទី ១៩ - ៩ - ៧៩ ក្នុងពុទ្ធសីមាវត្តឧណ្ណាលោម មានសុឆន្ទៈ និងឧត្តមគតិដ៏មោះមុតខ្លាំងក្លា បានប្រមូលសៀវភៅក្បួន ច្បាប់ - គម្ពីរដីកាផ្សេងៗ មានព្រះត្រៃបិដកជាដើម ។ល។ និង ។ល។ ដែលសេសសល់ពីការបំផ្លិចបំផ្លាញនៃជនក្បត់ ប៉ុល - ពត , អៀង - សារី មកដាក់កល់ទុកទីនេះ ដើម្បីជាធម្មទានសម្រាប់កុលបុត្រ - កុលធីតាជំនាន់ក្រោយរៀនសូត្រ ។

ដោយវីរភាពដ៏ឧត្តុង្គឧត្តម នៃការប្រមែប្រមូលគម្ពីរដីកាទាំងនោះ អាត្មាភាព សូមឧទ្ទិសភាគផលនៃផលានិសង្សនេះ ជូនចំពោះ :

- រណសិរ្ស និងក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ។
- ចំពោះយុទ្ធជន - យុទ្ធនារី ដែលបានពលីជីវិត ដើម្បីកសាង - ការពារមាតុប្រទេស ។
- ចំពោះ មាតា បិតា គ្រូឧបជ្ឈាយ៍អាចារ្យ ប្រជាជនទូទាំងប្រទេស ដែលបានចែកស្ថានទៅកាន់បរលោកក្តី រស់នៅក្តី ទទួលឥដ្ឋមនុញ្ញផលរៀងៗ ខ្លួនតទៅកុំបីខានឡើយ ។

ធ្វើនៅវត្តឧណ្ណាលោម ថ្ងៃទី ៩ ធ្នូ ១៩៧៩

ភិក្ខុ **អ៊ុត - ស៊ុំ**

ព.ស. ២.៥០០

បុណ្យ ព. ស. ២៥០០

# ឥណ្ឌៀយាត្រា



រៀបរៀងដោយ

ព្រះគ្រូសីលសំវរញ្ញាណ (ឡុង-ទូ)

គង់នៅ វត្តឧណ្ណាលោមក្រុងភ្នំពេញ

ធ្វើនៅថ្ងៃសុក្រ ៥កើតខែពិសាខ

ត្រូវនឹងថ្ងៃទី ៣ ខែឧសភា

គ. ស. ១៩៥៧

ព. ស. ២.៥០០

# អារម្ភបទ

ឥណ្ឌៀយាត្រានេះ ខ្ញុំបានរៀបរៀងឡើងដោយខ្ញុំបានទៅទស្ស-នាការនៅប្រទេសឥណ្ឌៀក្នុងរវាងខែធ្នូ ព.ស. ២.៥០០ ដោយបំណងថាស្ថានដែលសំខាន់ផ្សេង មានពោធិគយាក្នុវិការៈ, គិជ្ឈកូដជាដើម ពួកពុទ្ធបរិស័ទឲ្យបានដឹងបានឮតាមដំណាល តែក្នុងគម្ពីរខាងពុទ្ធសាសនាតាំងពីព្រេងនាយមក, តែមិនបានឃើញផ្ទាល់ដោយមំសចក្ខុ សម្រាប់ជនអ្នកត្រូវការឃើញទូទៅ ។

ហេតុនេះបានជាខ្ញុំរៀបរៀងរឿងនេះ ដើម្បីបំពេញសេចក្ដីត្រូវការដល់ជនដែលចង់ឃើញពិតប្រាកដដោយភ្នែក ។

លុះរៀបរៀងចប់ហើយ បានយកទៅប្រគេនចំពោះសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក សូមឲ្យជួយពិនិត្យកែតម្រូវពាក្យខ្វះដោយអន្ទើៗ លោកក៏យកព្រះហឫទ័យមេត្តាផ្ទៀងពិនិត្យឲ្យបានត្រឹមត្រូវសព្វគ្រប់ ។ ទាំងបានប្រគេនទៅព្រះគ្រូញាណសត្ថា ប៉ែន-សុខ សូមឲ្យជួយផ្ទៀងសំណៅពុម្ព ។

ព្រះគ្រូសីលសំវរញាណ (ឡុង-ទូ)

# ឧទ្ទិសកថា

# របស់

# ពួកពុទ្ធបរិស័ទ ដែលបានចូលបោះពុម្ពសៀវភៅ

# គំណ្ណៀយាត្រានេះ

---

ព្រះពុទ្ធសាសនា តាំងពីបានមកប្រតិស្ឋាន នៅប្រទេសខ្មែរយើង រមែងរីកសាយឡើងជាលំដាប់តាំងពីអតីតកាលរៀងរហូតដល់បច្ចុប្បន្នកាល , បើទុកជាមានឧបសគ្គខ្លះ ក៏ព្រះពុទ្ធសាសនានៅមានល្បឿនជឿនលឿនជានិច្ច ដរាបមកដល់ថ្ងៃនេះ ។

តាំងពីព្រះសាក្យមុនីសម្ពុទ្ធ ជាគ្រូដើមរបស់យើងបរិនិព្វានទៅមកទល់នឹងថ្ងៃពេញបូណ៌មីខែវិសាខ ឆ្នាំរកានព្វស័កនេះ ព្រះជន្មាយុនៃព្រះពុទ្ធសាសនា បាន ២៥០០ឆ្នាំហើយ ។

បុព្វបុរសរបស់យើង ដែលបានបាត់បង់អាយុសង្ខារទៅកាន់បរលោកនាយហើយ មុនពេលពាក់កណ្ដាលព្រះពុទ្ធសាសនា រមែងសោកស្ដាយចង់ជួប, ចង់ឃើញ, ចង់ទាន់ពាក់កណ្ដាលព្រះពុទ្ធសាសនានេះណាស់ ខ្លះមានដល់ទៅសម្រក់ទឹកភ្នែកក៏មាន ។

យើងដែលបានទាន់ពេលពាក់កណ្ដាលព្រះពុទ្ធសាសនានេះ ចាត់

ទុកជាមានកត្ត, មានលាភយ៉ាងធំបំផុត ដែលនឹងត្រូវបានទទួលសុខសុវត្ថិភាពតទៅ ។

ហេតុនេះហើយ បានជានៅវេលាបុណ្យសម្ពោធពាក់កណ្ដាលព្រះពុទ្ធសាសនានិងព្រះសក្យមុនីចេតិយ ទុកជាអនុស្សាវរីយ៍ទានព្រះពុទ្ធសា-សនានៅប្រទេសខ្មែរយើង ក្រោមការដឹកនាំនៃព្រះពររដ្ឋាភិបាលព្រមទាំងប្រជាជាតិខ្មែរទាំងមូល ទាំងបព្វជិតនិងគ្រហស្ថ ដែលបានផ្ដើមធ្វើឡើង នៅប្រទេសខ្មែរទាំងមូលចាប់ពីថ្ងៃអាទិត្យ ១៤ កើតខែពិសាខ ឆ្នាំរកានព្វស័ក ព.ស. ២៥០០ ដរាបដល់ថ្ងៃសៅរ៍ ៥ រោចខែ ឆ្នាំដដែល ព.ស.២៥០០ ។

យើងខ្ញុំមានពយនាមខាងក្រោមនេះ បានចូលបោះពុម្ពសៀវភៅ “ឥណ្ឌៀយាត្រា” នេះចែកជាធម្មទានទុកជាទីរលឹកនិងជាទីគោរពចំពោះព្រះពុទ្ធសាសនា ដោយមានគោលបំណងដូចតទៅ

១– សូមឧទ្ទិសភាគផលនេះជូនដល់វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់យើង មានមាតាបិតាជាដើម សុំឲ្យបានសម្រេចនៅឥដ្ឋមនុញ្ញផលវិបុលសុខសព្វប្រការ ។

២– សូមឲ្យប្រជាជាតិខ្មែរទាំងមូលបានឈានដំណើរដើរទៅកាន់ការព្យធម៌និងវឌ្ឍនធម៌ដោយរួសរាន់ ។

៣ សូមឲ្យព្រះពុទ្ធសាសនារីកសាយទូទៅតាំងពីកតពេលោកដរាប

គ្រប់៥០០០ព្រះវស្សា ។

៤- សូមឲ្យសន្តិភាពសាកលលោក កើតមានឡើងដោយបរិបូណ៌ ។

៥ - សូមឲ្យយើងខ្ញុំ បានប្រកបដោយវិជ្ជធម្មិកសុខទីងសម្បាយពិក-

សុខជាតិយេក្រពេតរៀងទៅ ។

ចិរំ តិដ្ឋតុ លោកស្មឹ

សម្មាសម្ពុទ្ធសាសនំ

សូមឲ្យពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធរុងរឿងក្នុងលោកអស់

កាលជាអង្វែងតទៅ ។

# នាមអ្នកដែលបានចូលបោះពុម្ពសៀវភៅនេះ

១— ពួកបំបៃ នៅក្រុងភ្នំពេញ

២— ឧបាសក លី-សាមហោ ឧបាសិកា សាន់-ទៀង

៣— ,, លឹម-ឈឺវវ៉ឡេន៍

៤— ,, ឡុក-គឹម ,, ទ្រី

៥— កុមារី ឡុក-សាវណ្ណ

៦— ,, សួរ-ឆេងលី

៧— ,, ហាង-ផាង ឧបាសិកា សួរ-មុយ

៨— ,, យិត-នាក់ ,, នួន-ពៅ

៩— ,, -នាង

១០— ,, យិត-ជ្រាន

១១— ,, គ្រិស

១២— ,, គឹម-បា

១៣— ,, អ៊ឹង-ទូច

១៤— ,, ប៉ូ ,, កៀវ

១៥— លោកអនុសេនីយ៍ទោ ណុប-អ៊ូច

១៦— ,, មាស-រិក

# អំពីស្ថានភ្នំអាជិន្តា



ភ្នំអាជិន្តា Ajenta

ភ្នំអាជន្តាមានគូហា ២៩តាំងតូច-ធំគូហាទាំង ២៩នេះបែកជា៥ផ្នែកៈ

១.– ត្រង់រូបចម្លាក់ព្រះកែ្នរបស់ព្រះអង្គតែនលេចមាន១០គូហា ។

២.– ត្រង់រូបចម្លាក់ព្រះអង្គលើកព្រះហស្តទាំងសងខាងមាន ១០ គូហា ។

៣.– ត្រង់រូបចម្លាក់ព្រះអង្គលើកព្រះហស្តម្ខាងមាន៥គូហា ។

៤.– ត្រង់រូបចម្លាក់ព្រះអង្គបរិនិព្វានមាន១គូហា, រូបចម្លាក់នោះ បណ្តោយ ១៦ ម.ទទឹង ២ម. មានព្រះមហាកានទុគន់ឧបព្រះបាទព្រះអង្គ ឃំសោកទឹកសាវ័ក្រព្រមទាំងពួកភិក្ខុសង្ឃគង់ខាងក្រោមមួយជួរ ទីងពីខាង

លើមានពួក ទេវតា, ឥន្ទ្រ, ព្រហ្មបាចផ្កាមន្ទារវបុស្បមកថ្វាយព្រះអង្គ ។ ក្នុងគូហាព្រះអង្គបរិនិព្វាននោះ មានរូបចម្លាក់ព្រះអង្គ តាំងពីប្រសូតរហូតដល់បរិនិព្វានទឹងរូបចម្លាក់ទេវតា, ឥន្ទ្រ, ព្រហ្ម ព្រមទាំងរូបចម្លាក់ឯទៀត ។ ភ្ជាប់ទឹងថ្មផ្ទាំងគូហានោះជាច្រើន ។

៩.– ត្រង់រូបចម្លាក់ស្តូប នៅក្នុងគូហាទាំងពីរនោះ គឺៈ មានរូបព្រះឥសូរព្រះនារាយណ៍ ព្រមទាំងសត្វពាហនៈឆ្លាក់ភ្ជាប់ទឹងផ្ទាំងនោះជាច្រើន ។

រូបចម្លាក់ខាងលើទាំងអស់សុទ្ធតែធ្វើនៅថ្មភ្នំនោះតែម្តង ។ គូហា-ទាំង២៨នេះ មានពួកមហាជនទៅគោរពបូជាជាច្រើនតាមការចូលចិត្ត ។

ភ្នំអាជន្តានេះនៅចម្ងាយពីទីក្រុងគោប៉ាលប្រហែលចំនួន ២៥០ គីឡូម៉ែត្រក្រុងនេះពីដើមហៅថាក្រុងគោសម្ពី ។

ភ្នំអាជន្តានេះមានអូរកាត់នៅចន្លោះកណ្តាល ។

---

## អំពីស្ថានភ្នំសញ្ជី

សញ្ជីនោះមានច្រើនសណ្ឋានគឺ. ព្រះស្តូបបញ្ចុះព្រះអរហន្តធាតុនៃព្រះមហាសារីបុត្តទឹងព្រះមហាមោគ្គល្លានទឹងព្រះស្តូបឯទៀតតូច- ធំជាច្រើន ព្រមទាំងមានគុដិគូហាបែកបាក់នៅសល់តែតួរាងប៉ុណ្ណោះ ។ ព្រះស្តូបធំ

១, តូប១ ព្រះបាទអសោកកសាងពីក្នុងកាលពុទ្ធសតវត្សរ៍ទី ៣ ។ ព្រះស្តូបពីរទៀតនៅឆ្ងាយពីគ្នាមិនដឹងជានរណាកសាងទេ ។ ព្រះស្តូបមួយទៀតទើបតែកសាងសម័យបច្ចុប្បន្ននេះបានបញ្ចុះព្រះអរហន្តធាតុព្រះមហាសារីបុត្តនិងព្រះមហាមោគ្គល្លាន ដែលមហាជនខ្មែរបានជួយចេញប្រាក់កសាងផងដែរ ។



ភ្នំសញ្ចី Sanchi

សសរបីដើមព្រះបាទសុង្គៈនិងព្រះបាទគុប្តៈកសាងពីសតវត្សរ៍ទី ២មុន គ.ស. ។ នៅក្នុងសញ្ចីនោះ អ្នករាជការស្រុកគេបានរៀបរយតាំងវត្ត

បុរាណផ្សេងៗ មានចម្លាក់ថ្មជាដើម ដែលឥឡូវបាក់បែកអស់ទៅហើយ ទុកសម្រាប់មហាជនទូទៅចូលមើល ។

មហាស្តូបសញ្ចីនេះ តាំងនៅលើភ្នំសញ្ចី ។ ភ្នំសញ្ចីនេះ នៅក្នុងអាណាព្យាបាលក្រុងគោប៉ាល ។ សព្វថ្ងៃនេះមានព្រះសង្ឃនិមន្តពីលង្កាទ្វីបមក នៅថែរក្សារបស់តាំងនោះ ធ្វើវត្តនៅជើងភ្នំប្របចំណតអយស្ម័យយាន ។

---

## ព្រះមុខចេតិយ

ព្រះមុខចេតិយនេះ នៅកន្លែងដែលព្រះអង្គទ្រង់ជួបបញ្ចវគ្គិយភិក្ខុក្នុងពេលដែលព្រះអង្គកំពុងតែយាង ទៅសំដែងធម៌នៅមិគទាយវ័ន សព្វថ្ងៃនេះអ្នកស្រុកគេហៅថា សារណាថ ។

## ព្រះធម្មិកចេតិយ

ព្រះធម្មិកចេតិយនេះ នៅកន្លែងដែលព្រះអង្គទ្រង់សំដែងធម្មចក្ក ប្រោសបញ្ចវគ្គិយភិក្ខុ ។ នៅក្បែរធម្មិកចេតិយនោះ មានវត្តបុរាណ បាក់បែកនៅសល់តែខឿនខាងក្រោមនឹងនៅផ្នែកខាងជើងធម្មិកចេតិយ មានសួនសត្វ ប៉ុន្តែសួនសត្វនោះមិនមែនដូចសួនសត្វយើងទេ គឺ សួនសត្វនោះគេយកលួសបន្លាទៅហ៊ុមព័ទ្ធព្រៃនោះ ហើយសត្វដែល នៅក្នុងទីនោះតាំងប៉ុន្មានគេយកចំណីអាហារទៅដាក់ឲ្យវាស៊ីយូរៗទៅម្តង

ជាសត្វដែលយើងយកមកដាក់ក្នុងទ្រុងចិញ្ចឹមដែរ ។ ខាងត្បូងធម្មិកចេតិយមានធម្មសាលាជារបស់មហាពោធិសមាគមប្រទេសឥណ្ឌៀ មានព្រះវិហារទើបតែកសាង ហៅថា មូលគន្ធកុដិមហាវិហារ មានកំពលបីនៅជ្រុងឦសានធម្មិកចេតិយ, មានដើមពោធិ៍ ១ ដើមទៀតដាំកល់ព្រះពុទ្ធរូបនៅក្រោមដើមពោធិ៍នោះ ។



សាណ៌ាថ Saranath

# អំពីស្ថានកុសិនារា

កុសិនារានេះជាកន្លែងដែលព្រះអង្គទ្រង់បរិនិព្វាន មានគូហា ព្រះស្តូបកុដិបាក់បែកជាច្រើនទីង មានវត្តភូមា ១ នៅជ្រុងឦសានគូហា ។ សព្វថ្ងៃនេះ អ្នកស្រុកកំពុងរៀបចំជាថ្មីឡើងវិញ ។

កន្លែងបូជាព្រះបរមសពព្រះអង្គនៅចម្ងាយប្រហែលមួយ គ.ម. កន្លះ ពីកន្លែងបរិនិព្វាន ។ បំណែកព្រះអង្គបរិនិព្វាន ៦ម. ដោយបណ្តោយ; ១មុ២០ ដោយទទឹង, ទទឹងព្រះបាទ ០មុ៥០, បណ្តោយព្រះបាទ ០មុ៨០, ព្រះភ័ក្ត្រ ០ មុ ៦០ ដោយបណ្តោយ, ០ មុ ៧០ ដោយទទឹង ។



កុសិនារា Kosaniya

# អំពីស្ថានវត្តជេតពន

វត្តជេតពន ជាវត្តដែលអនាថបិណ្ឌិកសេដ្ឋីកសាងថ្វាយព្រះអង្គជិតក្រុងសាវត្ថី ។ ក្នុងវត្តជេតពននេះមានកុដិជាច្រើន ប៉ុន្តែកុដិដែលមានឈ្មោះគង់នៅរហូតមកដល់សព្វថ្ងៃនេះគឺ៖ គន្ធកុដិ១,មហាកុដិ១,ធម្មកុដិ១, មានព្រះចេតិយតូចធំជាច្រើន ព្រមទាំងមានផ្លូវខ្វាត់ខ្វែងកាត់រកគ្នាទៅ-វិញទៅមកពេញតែក្នុងវត្ត ។

ឯកន្លែងព្រះធរណីស្រូបនាងចិញ្ចាតាំងនៅខាងទិសឦសាន ចម្ងាយអំពីវត្តជេតពនប្រហែលជា៥០០ម៉ែត្រ សព្វថ្ងៃនេះទៅជាត្រពាំងទឹកទៅហើយ ប៉ុន្តែគ្មានផលជាតិអ្វីផុះក្នុងទីនោះទេ ។ កន្លែងព្រះធរណីស្រូបទេវទត្តតាំងនៅទិសឦសានដែរ ប៉ុន្តែងាកទៅខាងជើងបន្តិច ចម្ងាយពីព្រះនាងចិញ្ចាប្រហែល៣០០ម៉ែត្រ, ចម្ងាយពីវត្តជេតពនប្រហែល១គីឡូម៉ែត្រនៅមានតែទឹកដូចត្រពាំងនាងចិញ្ចាដែរ ។

កន្លែងយមកបាដិហារតាំងនៅទិសឦសានដែរ ចម្ងាយពីវត្តជេតពនប្រហែល ១គីឡូម៉ែត្រកន្លះពីកន្លែងនោះ ពីដើមគេហៅថាអម្ពវន័(ព្រៃស្វាយ) សព្វថ្ងៃនេះមានដីទួលកំពស់ប្រហែល១០ម៉ែត្រ លើដីទួលនោះ មានព្រះស្តូបមួយ ប៉ុន្តែបាក់បែកអស់ទៅហើយ ។ ឯទីក្រុងសាវត្ថីនោះ គេហៅ

បង់ចោលទៅ សាងក្រុងថ្មីទៀត យូរណាស់ហើយ ,សព្វថ្ងៃគេហៅថាទីក្រុងសាវត្ថីចាស់នោះថា សះហេត-ម៉ះហេត ។



វត្តជេតពន  Wath Chet-Pôn Krong-Savthi

## អំពីស្ថានលុម្ពិនី

លុម្ពិនីនេះជាកន្លែងព្រះអង្គប្រសូត  មានសសរស្តម្ភសំខាន់១ដែលមាននៅក្នុងរូបផ្តិតជាប់មកនេះ ។ ខាងកើតសសរស្តម្ភមានគូហា ១ ។ ក្នុងគូហានោះមានរូបចម្លាក់ព្រះនាងសិរិមហាមាយា កាលដែលព្រះអង្គកំពុងប្រសូត ។ ខាងកើតគូហានោះមានពោធិព្រឹក្ស១ដើម ។ នៅខាងត្បូង

គូហានោះមានស្រះ១ ៗ ខាងទិសនិរតីស្រះនោះមានវត្តកូមា១កំពុងតែ
កសាងជិតហើយ ៗ ដីទួលបីកន្លែងនៅក្នុងលុម្ពិនីនោះ។ សព្វថ្ងៃនេះពជការ
កំពុងតែរៀបចំឲ្យមានរបៀបរៀបរយល្អ ៗ



លុម្ពិនី Lumpini

# អំពីស្ថានភ្នំគិជ្ឈកូដ

ភ្នំគិជ្ឈកូដនេះនៅពីខាងកើតក្រុងរាជគ្រឹះជាប់នឹងភ្នំវេបុល្យ: នៅតាមផ្លូវទៅភ្នំគិជ្ឈកូដកណ្ដាលក្រុងរាជគ្រិះ នៅសល់បុរាណវត្ថុ ៣ កន្លែងគឺ:

១– ចេតិយឈ្មោះមហិយាម័ត ។

២– គុកដែលព្រះបាទអជាតសត្រូវដាក់ព្រះបាទពិម្ពិសារជាបិតារបស់ព្រះអង្គនោះឈ្មោះពិម្ពិសារ ។



ភ្នំគិជ្ឈកូដ Gajjhakot (Rajagir)

៣– វត្តជីវកម្ពវ័ន ដែលកុមារពេទ្យឈ្មោះជីវកថ្វាយដល់ព្រះបរមគ្រូ ទីអស់ទាំងនេះនៅសល់កំពែងជញ្ជាំងនិងស្នាមឥដ្ឋតែប៉ុណ្ណោះ ។

ភ្នំគិជ្ឈកូដនេះ សព្វថ្ងៃនៅមានរូបថ្មជាច្រើន និងស្នាមព្រះចេតិយបាក់បែកបីបួនកន្លែង តាំងទៅលើកំពូលតូចលយចេញមកខាងលិច មានគន្ធកុដិដែលព្រះបាទពិម្ពិសារគេសាងថ្វាយព្រះអង្គ ប៉ុន្តែសព្វថ្ងៃនេះបាក់បែកអស់ហើយ នៅសល់តែគ្រឹះដូចក្នុងរូបភាពនេះស្រាប់ ។

ម្យ៉ាងទៀតកន្លែងដែលទេវទត្តប្រមៀលថ្មត្រូវព្រះបាទព្រះអង្គនោះ នៅចំត្រង់ចង្អៀតភ្នំកណ្ដាលផ្លូវដែលឡើងទៅលើភ្នំគិជ្ឈកូដ ។ ទេសភាពក្រុងរាជគ្រឹះគួរឲ្យពិតពិលរមិលមើល ណាស់មានភ្នំព័ទ្ធជុំវិញគឺ ភ្នំវេភារៈ, វេបុល្លៈ, ឥសិគិលិ, បណ្ឌវៈ គិជ្ឈកូដ ភ្នំដែលព្រះបាទពិម្ពិសារស្តេចយាងទៅជួបព្រះអង្គដំបូងបង្អស់គឺ ភ្នំគិជ្ឈកូដ ។ ឯក្រុងរាជគ្រឹះសម័យនេះតាំងនៅខាងជើងខាងក្រៅរង្វង់ជួរភ្នំ ក្នុងបច្ចុប្បន្ននេះគេហៅថា រាជគិរ៍ Rajagir ជាផ្សារតូចតាចប៉ុណ្ណោះទេ ។

ចុះពីលើភ្នំគិជ្ឈកូដមកវិញ ទៅមើលវត្តវេឡុវ័ន ដែលព្រះបាទពិ-ម្ពិសារថ្វាយព្រះសម្មាសម្ពុទ្ធមុនដំបូងបង្អស់ វត្តវេឡុវ័នមិនមានសល់អ្វីបន្តិចបន្តួចឡើយ ជាដីរាបធេង ហើយគេដាំសួនច្បារយ៉ាងល្អស្អាត កណ្ដាលវត្តមានស្រះមួយ យ៉ាងល្អរាងបួនជ្រុងមានទឹកថ្លាស្អាត; ខាងលិចខាងក្រោយស្រះមានព្រះពុទ្ធរូបមួយព្រះអង្គ តែព្រះពុទ្ធរូបនេះគេសាងមកពេលក្រោយទៀតទេ បើតាមស្មានប្រហែលជាជំនាន់មហាវិទ្យាល័យនា

លន្ធា; នៅខាងជើងវត្តវេឡុវ័ននេះ មានកំផែងវាំងព្រះបាទអជាតសត្រូវ ដែលសាងនៅខាងក្រោយបរិវេណភ្នំ ដែលជាវាំងរបស់ព្រះបាទពិម្ពិសារ កំផែងវាំងនេះនៅជញ្ជាំងកំផែងខ្ពស់ខ្លះទាបខ្លះ រៀបថ្មលាតសន្ធឹងបណ្តោយ ពីខាងលិចទៅខាងកើត បណ្តោយប្រហែល ១ គីឡូម៉ែត្រកន្លះ ទទឹងចំនួន ១ គីឡូម៉ែត្រ ត្រង់ទីកណ្តាលវាំងនៅជាស្រែដាំស្រូវនឹងដាំដំណាំបន្លែបន្ការផ្សេងៗទៅហើយ ។

## អំពីស្ថានភ្នំវេភារៈ



ភ្នំវេភារៈ

Vepharak
(Ra agir)

ភ្នំវេភារៈនេះ នៅក្នុងនគររាជគ្រឹះជាកន្លែងដែលព្រះមហាកស្សបៈ លើកបឋមសង្គាយនា កាលពីព្រះអង្គបរិនិព្វានទៅបានបីខែ ។ ពីជើងភ្នំរហូតទៅដល់កន្លែងធ្វើបឋមសង្គាយនានោះចម្ងាយ៥គីឡូម៉ែត្រត្រង់កន្លែងនោះមានរូងពីររូងទី១ មានកំពស់មាត់ ៥ ម៉ែត្រ , រូងទី ២ កំពស់ ៤ ម៉ែត្រ បណ្ដោយមុខរូង៣៩ម៉ែត្រ ទទឹង៦ម៉ែត្រ ។ សព្វថ្ងៃនេះមានវិហារពួកជេន ៣, ឥណ្ឌូ ២ តាំងនៅលើភ្នំនោះ ។ នៅចង្កេះភ្នំមានគុហាមួយដែលព្រះសារីបុត្តធ្វើសមាធិ ។ នៅជើងភ្នំមានគុហាឥណ្ឌូមួយនៅជិតគុហានេះគេធ្វើអាងបួនប្រាំអន្លើមានទឹកក្ដៅឧណ្ហៗហូរចេញពីភ្នំមិនដាច់ដែលមហាជនតែងនាំគ្នាទៅមុជនៅទីនោះ ។

---

# អំពីទីកន្លែងព្រះអង្គធ្វើទុក្ករកិរិយា

កន្លែងព្រះអង្គធ្វើទុក្ករកិរិយានេះ នៅនឹងចង្កេះភ្នំឌុង្គៈ សរីបចម្ងាយពីពុទ្ធគយាប្រហែល៨គីឡូម៉ែត្រ នៅជិតនោះមានស្ទឹង នេរញ្ជកពីខាងលិចស្ទឹងទុរវេលាពីខាងកើតមានគុហាមួយ នៅក្នុងគុហានោះមានព្រះពុទ្ធរូបមួយព្រះអង្គ, នៅពីខាងមុខមានរូងភ្នំ ដែលព្រះអង្គគង់ធ្វើទុក្ករកិរិយា ។ សព្វថ្ងៃនេះមានព្រះសង្ឃជាតិទីបេតនៅថែទាំនោះ ។ ក្នុងឱកាសបុណ្យ ព.ស.២៥០០ មានជនច្រើនជាតិច្រើនសាសន៍យកទង់ទៅចងដេរដាស

តាមសេចក្ដីប្រាថ្នារៀងៗខ្លួន ។ ភូមិភាគត្រង់ទីនេះជាដីកោះ ហៅថា



ធ្វើទុក្ករកិរិយា Tukkarak-Kiriya

ឧរុវេលប្រទេសសេនានិគមជាភូមិរបស់នាងសុជាតា, អជបាលនិគ្រោធ ជាមហាឋានទី៥ឋិតនៅក្នុងភូមិភាគនេះ ។

# អំពីស្ថានពុទ្ធគយា

ពុទ្ធគយា ជាកន្លែងដែលព្រះអង្គទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។

នៅបច្ចុប្បន្ននេះជាទីសំវេជនីយដ្ឋាន ១ យ៉ាងស្ងប់ស្ងាត់ រមណីយដ្ឋាន គួរដល់អ្នកហ្វឹកហាត់វិបស្សនាកម្មដ្ឋាន គឺជាបរិវេណធំ តាំងនៅត្រង់



ពុទ្ធគយា

Buddhagaya

ដីទីទាបមានដីទួលខ្ពស់ជុំវិញ កណ្ដាលបរិវេណនេះមានព្រះមហាចេតិយ

១ធំកំពស់ប្រហែល ៦០ម៉ែត្រ៤ជ្រុងពីជ្រុងមួយទៅជ្រុងមួយប្រហែល ២០ ម៉ែត្រ មាត់ទ្វារបែរទៅខាងកើត ឯដើមព្រះមហាពោធិព្រឹក្សតាំងនៅជាប់ពីខាងក្រោយព្រះមហាចេតិយ, រតនបល្ល័ង្កដែលគេសាងឡើងដោយព្រះបាទអសោកធ្វើដោយថ្មតាំងនៅខាងកើតគល់ពោធិ៍ត្រង់ចន្លោះរវាងពោធិព្រឹក្សនឹងព្រះមហាចេតិយ នៅខាងត្បូងផែបជាប់នឹងខឿនព្រះមហាចេតិយគេសាងចង្កមនដ្ឋាន កន្លែងដែលព្រះអង្គចង្ក្រម ៧ ថ្ងៃក្នុងសត្តាហៈទី ២, ចង្កមនដ្ឋាននេះគេធ្វើជាពាំងផ្កាឈូក ១៩ សម្រាប់ទ្រង់ជាន់ព្រះអង្គ តាំងនៅពីខាងជើងជិតជាប់គ្នានឹងព្រះមហាចេតិយ; នៅទិសឦសានព្រះមហាចេតិយមានចេតិយ១ តូចបន្តិចឈ្មោះអនិមិសក្ខចេតិយ តាំងនៅលើដីទួលជាទីដែលព្រះអង្គទ្រង់ឈរសំឡឹងមកព្រះមហាពោធិព្រឹក្ស៧ថ្ងៃ ក្នុងសត្តាហៈទី ៣ នៅចម្ងាយពីព្រះមហាពោធិព្រឹក្សប្រហែលជាង ៤០ ម៉ែត្រ ។

នៅខាងជើងស្មើរពាយ័ព្យមហាពោធិព្រឹក្សមានព្រះចេតិយតូចឥតមានកំពូលប្រហែល ៤ ម៉ែត្រ ៤ ជ្រុងឈ្មោះរតនឃរចេតិយដែលព្រះអង្គទ្រង់គង់ ៧ ថ្ងៃពិចារណាអភិធម្មបិដកក្នុងសត្តាហៈទី ៤ ទីនេះនៅចម្ងាយពីមហាពោធិព្រឹក្សប្រហែលជាង ២០ ម៉ែត្រ ។

នៅពីខាងត្បូងស្មើរអគ្នេយ៍ព្រះមហាចេតិយប្រហែល ៤០ ម៉ែត្រ

មានស្រះធំ ១ មានរបងព័ទ្ធជុំវិញយ៉ាងស្អាត ហើយមានសសរស្តម្ភព្រះបាទអសោក នៅចំកណ្តាលស្រះនេះឈ្មោះស្រះមុជលិន្ទដែលព្រះអង្គគង់លើរង្វេលនាគពេន ៧ថ្ងៃសោយវិមុត្តិសុខ ក្នុងសត្តាហៈទី ៦ រាងទំហំ៤ ជ្រុងប្រវែលជាង ២០ ម៉ែត្របួនជ្រុង ៗ

ក្នុងបរិវេណចេតិយមានព្រះចេតិយ , ព្រះស្តូបតូច – ធំជាច្រើនជាបរិវេណស្អាតស្អំស្រឡះស្រឡំគួរជាទីរីករាយ ៗ ក្នុងឱកាសបុណ្យ ព.ស. ២៥០០ នៅពុទ្ធគយានេះមានមហាជនគ្រប់សញ្ជាតិ : ទីបេ, លង្កា-ទ្វីប , ភូមា , នេប៉ាល , ថៃ , ប៉ាគីស្ថាន , ម៉ុងគោលី, ជប៉ុន , ភូតាន , ស៊ីគីមនិងកម្ពុជាជាដើម បានទៅធ្វើសក្ការបូជានមស្ការពោធិបល្ល័ង្កនិងក្នុងព្រះវិហាររួចហើយនាំគ្នាសូត្រធម៌តាមសូរសព្ទបាលីរៀង ៗ ខ្លួនហែរប្រទក្សិណបីជុំ ៗ